# II - ឯកសារគណៈរដ្ឋមន្ត្រី

## ១. អនុក្រឹត្យ

*រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤*

### អនុក្រឹត្យលេខ ៦៧ អនក្រ
### ស្តីពីការចាត់ទុកជានិរាករណ៍នូវប្រកាសមួយចំនួន
### របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជ ក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ពិសេសមាត្រា ២៨
- ដោយពិនិត្យឃើញថា ការចេញប្រកាសមួយចំនួន ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការដែលចុះ ហត្ថលេខាដោយឯកឧត្តម សម រង្ស៊ី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងលក្ខណៈ ប្រញាប់ប្រញាល់ទៅលើកិច្ចការដែលមិនមាន លក្ខណៈជាបន្ទាន់

### សំរេច

**មាត្រា ១ :** ចាត់ទុកជានិរាករណ៍ នូវប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមានខាងក្រោម :

- ប្រកាសលេខ ២៨០ ប្រក.ន.ប.សហវ ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការផ្ទេរភារកិច្ចមន្ត្រី រាជការចំនួន ១២ នាក់ អោយទៅបំរើការងារនៅទីចាត់ការគយ និង រដ្ឋាករ ។
- ប្រកាសលេខ ២៨១ ប្រកនប. សហវ ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតការិយាល័យ គយ និង រដ្ឋាករត្រួតពិនិត្យផ្លូវគោក ។
- ប្រកាសលេខ ២៨២ ប្រកនប សហវ ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការផ្ទេរភារកិច្ចមន្ត្រី រាជការ ចំនួន ៥៧ នាក់ អោយទៅបំរើការងារនៅទីចាត់ការគយ និង រដ្ឋាករ ។
- ប្រកាសលេខ ២៨៣ប្រកនសហវ ចុះថ្ងៃទី១៥ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ ។

-ប្រកាសលេខ ២៩៩ ប្រកន.បសហវ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការផ្ទេរភារកិច្ច មន្ត្រីរាជការ ។

-ប្រកាសលេខ ៣០០ ប្រកនប.សហវ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការចំនួន ២២ នាក់ អោយទៅបំរើការងារនៅទីចាត់ការគយ និង រដ្ឋាករ ។

-ប្រកាសលេខ ៣០២ ប្រកនប.សហវ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការលុបចោលទាំងស្រុងលិខិតបទដ្ឋាន នៃប្រកាសលេខ ២១៧ ប្រកនប.សហវ ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ ពីររូប ។

-ប្រកាសលេខ ៣០៦ ប្រកនប.សហវ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការតែងតាំង និងផ្ទេរភារកិច្ចមន្ត្រីរាជការ គយ ចំនួន ពីរនាក់ ។

-ប្រកាសលេខ ៣០៨ ប្រកនប.សហវ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការតែងតាំងមន្ត្រីរាជការគយ ចំនួនមួយ នាក់ ។

-ប្រកាសលេខ ៣០៩ នប.ប្រក សហវ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជ ការចំនួន បីនាក់ ។

-ប្រកាសលេខ ៣១០ ប្រកនប.សហវ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជ ការ របស់ទីចាត់ការគយ និង រដ្ឋាករ ចំនួន ប្រាំនាក់ ។

-ប្រកាសលេខ ៣១១ ប្រកនប.សហវ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ ចំនួនពីរនាក់ អោយទៅបំរើការងារទៅទីចាត់ការគយ និង រដ្ឋាករ ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***